01043412

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**លេខ/No: D212/1/2/2**

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ១៤)

| | | |
|---|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន | ប្រធាន |
| | ចៅក្រម Rowan DOWNING | |
| | ចៅក្រម ន័យ ថុល | |
| | ចៅក្រម Chang-Ho CHUNG | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 12 / 2014
ម៉ោង (Time/Heure): 13:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ (សំណៅកោសល្យ)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់**

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍៖**

សូ មូស្សេទ្ទី
Suzana TOMANOVIC

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា

Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Barnabe NEKUI
Lyma NGUYEN
Christine MARTINEAU
Beini YE

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

**វ៉ែន ពៅ**

Laure DESFORGES
Herve DIAKIESE
Ferdinand DIAMMEN-
NZEPA

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់" ដែលបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍") បានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យផ្តល់ការបំភ្លឺស្តីពីសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក្នុងគោលបំណងចោទប្រកាន់ជនសង្ស័យ ដោយអះអាងថា "មានលទ្ធភាពពិតប្រាកដ" ដែលថា គាត់អាចត្រូវបានកោះហៅ ដើម្បីធ្វើការចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") ហើយថា ច្បាប់មិនបានចែងច្បាស់អំពីសុពលភាពនៃដីកាកោះនោះទេ ("សំណើសុំការបំភ្លឺ")[2]។

២. នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ ស.ច.ស.អ បានបំភ្លឺថា "អនុលោមតាមច្បាប់ជាធរមាន ដីកាកោះហៅជនសង្ស័យណាម្នាក់ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ គឺមានសុពលភាព និងជាប់កាតព្វកិច្ច" ("សេចក្តីសម្រេចដែលរងការជំទាស់")[3]។ ស.ច.ស.អ បានសង្កត់ធ្ងន់ថា សំណើសុំការបំភ្លឺលើកឡើងនូវសេណារីយ៉ូជាសម្មតិកម្មមួយ តែគាត់ជ្រើសរើសទទួលយកសំណើ ដោយសារគាត់យល់ថា សហមេធាវីការពារក្តីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មានការយល់ខុសអំពីផ្នែកដ៏សំខាន់នៃកិច្ចស៊ើបសួរ[4]។ ស.ច.ស.អ បានបដិសេធទឡ្ហីករណ៍របស់សហមេធាវីដែលថា លក្ខខណ្ឌតម្រូវដែលត្រូវមាន "ភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា" សម្រាប់ចោទប្រកាន់ បង្ហាញឱ្យឃើញពីអសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់

---

[1] ឯកសារ D212/1/2/1។

[2] សំណើរបស់ [redacted] សុំការបំភ្លឺអំពីសុពលភាពនៃដីកាកោះ ដែលសហចៅក្រមស៊ើបអង្កេតតែម្នាក់បានចេញ ក្នុងគោលបំណងដើម្បីធ្វើការចោទប្រកាន់មកលើរូបគាត់ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D212។

[3] ការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចុះកាលបរិច្ឆេទដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ឯកសារ D212/1 កថាខណ្ឌ ១៣។

[4] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦ និង ៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ដែលថា "គ្មានមូលដ្ឋានត្រឹមត្រូវ" និងគ្មានខ្លឹមសារ[5]។ ស.ច.ស.អ បានសម្រេចថា "នៅក្នុងកាលៈទេសៈដែលបទប្បញ្ញត្តិនៃវិធាន ៧២ នៃវិធានផ្ទៃក្នុង ត្រូវបានអនុវត្តយ៉ាងពេញលេញនោះ សុពលភាពនៃដីកាកោះហៅជនសង្ស័យណាម្នាក់ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ គឺមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ជាធរមាន ជាពិសេសនៅក្នុងមាត្រា ៥ និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២ នៃវិធានផ្ទៃក្នុង"[6] ព្រមទាំងបានយោងទៅដល់សេចក្តីសម្រេចនាពេលថ្មីៗរបស់អង្គបុរេជំនុំជម្រះ ចំពោះបញ្ហានេះ ដែលលើកឡើងនៅក្នុងសេចក្តីសម្រេចមួយចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ពាក់ព័ន្ធនឹងជនសង្ស័យម្នាក់ទៀតនៅក្នុងរឿងក្តីតែមួយ[7]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលសំណៅកោសលុបនៃសេចក្តីសម្រេចដែលបានលើកឡើងនោះ ដែលត្រូវបានចាត់ថ្នាក់ជាឯកសារ "សម្ងាត់បំផុត" នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៤[8]។

៣. នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចដែលរងការជំទាស់ ហើយ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ និង ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ គាត់បានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេស និងភាសាខ្មែរជាបន្តបន្ទាប់។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារការសម្រេចផ្ទុយរបស់ ស.ច.ស.អ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[9]។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកទឡ្ហីករណ៍ថា ការសម្រេចនេះជាការផ្ទុយទៅនឹងការសម្រេចរបស់ ស.ច.ស.អ ដែលថា ត្រូវតែមាន "ភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា" ប្រឆាំងនឹងជនសង្ស័យ មុននឹងធ្វើការចោទប្រកាន់ ហើយម្យ៉ាងទៀត គាត់បែរជាសម្រេចថា ដីកាកោះហៅជនសង្ស័យអាចត្រូវបានចេញប្រកបដោយសុពលភាពដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯង ក្នុងគោលបំណងដើម្បី

---

[5] *ដូចយោងខាងលើ* កថាខណ្ឌ ១០។

[6] *ដូចយោងខាងលើ* កថាខណ្ឌ ១១។

[7] *ដូចយោងខាងលើ* កថាខណ្ឌ ១១ *ដោយយោងទៅដល់* សេចក្តីសម្រេចលើសំណើបន្ទាន់របស់ [កោសលុប] [កោសលុប] ឯកសារ A122/6.1/3 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើបន្ទាន់") កថាខណ្ឌ ១៤។

[8] ដីកាសម្រេចលើសំណើរបស់ [redacted] សុំឯកសារ A122/6.1/3។

[9] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៩។

ធ្វើការចោទប្រកាន់[10]។ ម្ចាស់បណ្តឹងឧទ្ធរណ៍យល់ឃើញថា "បើតាមនិយមន័យ នៅមានមន្ទិលសង្ស័យ និងភាពស្រពិចស្រពិលទៅលើភស្តុតាង ប្រសិនបើមានសហចៅក្រមស៊ើបអង្កេតណាម្នាក់មិនយល់ស្របទៅនឹងការចោទប្រកាន់នោះទេ"[11]។ ហេតុនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំអង្គបុរេជំនុំជម្រះ "មេត្តាឱ្យបញ្ជាក់ថា ដីកាកោះហៅជនសង្ស័យដែលមានសុពលភាព និងជាប់កាតព្វកិច្ច មិនអាចត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក្នុងគោលបំណងដើម្បីធ្វើការចោទប្រកាន់ទៅលើជនសង្ស័យបានទេ"[12]។

៤. ពុំមានការដាក់ចម្លើយតបណាមួយពីសហព្រះរាជអាជ្ញា ឬពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលដែលត្រូវបានកំណត់ឡើងដោយផ្លូវច្បាប់នោះទេ។

## II. ភាពទទួលយកបាន

៥. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានអះអាងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ៧៣ ឬ វិធាន ៧៤ នៃវិធានផ្ទៃក្នុង ដែលចែងច្បាស់ពីយុត្តាធិការរបស់អង្គបុរេជំនុំជម្រះទេ តែលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះគួរប្រកាសថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ វិធាននេះចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

**<u>វិធាន ២១. គោលការណ៍ជាសារវន្ត</u>**

> ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។

[10] *ដូចយោងខាងលើ* កថាខណ្ឌ ១៣។

[11] *ដូចយោងខាងលើ* កថាខណ្ឌ ១៣។

[12] *ដូចយោងខាងលើ* ទំព័រ ៨ (ភាសាអង់គ្លេស)។

៦. អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា គោលការណ៍ជាសារវ័ន្តដែលបានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវឱ្យមានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ដែល អ.វ.ត.ក ជាប់កាតព្វកិច្ចត្រូវអនុវត្តតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[13] មាត្រា ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[14] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[15] អាចតម្រូវថាសាលាក្តីនេះត្រូវប្រើប្រាស់ការបកស្រាយបែបបើកទូលាយចំពោះសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយត្រឹមត្រូវយុត្តិធម៌ និងចំពោះមុខ ហើយត្រូវរក្សាឱ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី[16]។ នៅពេលដែលអង្គហេតុ និងកាលៈទេសៈពិសេសតម្រូវ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍នានាដែលលើកឡើងពីសិទ្ធិជាសារវ័ន្ត ឬ "បញ្ហាធ្ងន់

---

[13] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

[14] ច្បាប់ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងវិសោធនកម្មដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

[15] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ១៣ ដល់ ១៨, ២៧។

[16] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 ("សាលដីកាលើចម្លើយតបរបស់ អៀង សារី") កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ ១៤) សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តីស្តីពីកំហុសក្នុងការបកប្រែ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ ២ ("សេចក្តីសម្រេចស្តីពីកំហុសក្នុងការបកប្រែ") កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។

ធួរនៃភាពត្រឹមត្រូវយុត្តិធម៌” អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[17]។ ទាក់ទងនឹងបញ្ហានេះ វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានផ្តល់សិទ្ធិដោយស្វ័យប្រវត្តិសម្រាប់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីទឡ្ហីករណ៍នានាដោយផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ទេ។ ដើម្បីឲ្យអង្គបុរេជំនុំជម្រះអាចអនុវត្តយុត្តាធិការលើបណ្តឹងឧទ្ធរណ៍តាមវិធាន ដែលបានលើកឡើងបាន ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈពិសេសៗនៃរឿងក្តី ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះ គឺជាការចាំបាច់ក្នុងការទប់ស្កាត់មិនឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបានដល់ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌។ នាពេលថ្មីៗនេះ អង្គបុរេជំនុំជម្រះសម្រេចមិនទទួលយកបណ្តឹងឧទ្ធរណ៍មួយទៀតរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ស្នើសុំការបំភ្លឺទៅលើច្បាប់ពាក់ព័ន្ធនឹងសេណារីយ៉ូបែបសម្មតិកម្ម ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[18]។ អង្គបុរេជំនុំជម្រះបានសម្រេចថា “សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ពុំតម្រូវថា ស្ថាប័នតុលាការត្រូវដោះស្រាយបញ្ហាផ្នែកអង្គច្បាប់ មុនពេលបញ្ហាទាំងនោះកើតឡើងពិតប្រាកដចេញពីសាវតារបរិបទ និងអង្គហេតុនៃបញ្ហាទាំងនោះឡើយ” និងបានសន្និដ្ឋានថា អង្គបុរេជំនុំជម្រះ “ពុំមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ”[19]។

៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីសំណើសុំការបំភ្លឺស្នើសុំមតិយោបល់ណែនាំទៅលើបញ្ហាជាសម្មតិកម្មក៏ដោយ ក៏ ស.ច.ស.អ បានជ្រើសរើសយកឆ្លើយតបចំពោះសំណើ ដោយសារគាត់យល់ថា សហមេធាវីការពារក្តីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មានការយល់ខុសអំពី “ផ្នែកដ៏សំខាន់នៃកិច្ចស៊ើបសួររបស់ អ.វ.ត.ក”[20]។ នាពេលនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំជំទាស់ទៅនឹងខ្លឹមសារ

---

[17] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣ ដល់ ១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣ *និង* សេចក្តីសម្រេចស្តីពីកំហុសក្នុងការបកប្រែ កថាខណ្ឌ ២ ដល់ ៦។

[18] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2។

[19] *ដូចយោងខាងលើ* កថាខណ្ឌ ៩។

[20] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦ និង ៧។

E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

នៃការបំភ្លឺរបស់ ស.ច.ស.អ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងស្នើឲ្យអង្គបុរេជំនុំជម្រះបង្ហាញការយល់ឃើញរបស់ខ្លួនចំពោះអង្គច្បាប់ ដោយលើកជាទឡ្ហីករណ៍ថា នេះជាផ្នែកមួយនៃសិទ្ធិរបស់គាត់ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់។ ដូចដែល ស.ច.ស.អ បានរម្លឹកនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់រួចមកហើយ អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា ដីកាកោះហៅជនសង្ស័យដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក្នុងគោលបំណងចោទប្រកាន់ជនសង្ស័យអនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង មានសុពលភាព ប្រសិនបើនីតិវិធីនៃការខ្វែងយោបល់គ្នាដែលមានចែងក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង ត្រូវបានអនុវត្តរួច[21]។ ចំពោះបទដ្ឋានសម្រាប់ការចោទប្រកាន់ជនសង្ស័យវិញ បទដ្ឋានត្រូវបានចែងច្បាស់ក្នុងវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។ ចំពោះករណីថាតើ ក្នុងករណីពិសេសនេះ ថាតើបទដ្ឋាននេះត្រូវបានបំពេញ ឬក៏អត់នោះ គឺជាបញ្ហាដែលមិនអាចយកមកពិនិត្យតាមបែបអរូបីបានទេ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា ការបកស្រាយច្បាប់របស់ ស.ច.ស.អ ដែលមានរៀបរាប់ក្នុងសេចក្តីសម្រេចដែលរងការជំទាស់ បានធ្វើឲ្យប៉ះពាល់សិទ្ធិរបស់គាត់ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់នោះ មិនមានមូលដ្ឋានទេ។

៨. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

[21] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើបន្ទាន់ កថាខណ្ឌ ១៤។

01043420



## III. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

**មិនទទួល** យកបណ្តឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ណី ថុល** **Chang-Ho CHUNG** **ហួត វុធី**